ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧៩១ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិ
# សម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច កម្ពុជា-បេឡារុស

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ១៣១ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញសេចក្តីប្រកាសរួមរបស់នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងនាយករដ្ឋមន្ត្រីនៃសាធារណរដ្ឋបេឡារុស ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៤ នៅទីក្រុងមីនស្គ សាធារណរដ្ឋបេឡារុស
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

ត្រូវបានបង្កើតគណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច កម្ពុជា-បេឡារុស ក្នុងគោលបំណងសម្របសម្រួល និងធានាប្រសិទ្ធភាពនៃការអនុវត្តសេចក្តីប្រកាសរួម និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធរវាងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋបេឡារុស។

# ជំពូកទី២
## សមាសភាព

**មាត្រា២ .-**

គណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច កម្ពុជា-បេឡារុស មានសមាសភាព ដូចខាងក្រោម៖

| | | | |
|---|---|---|---|
| ១. ឯកឧត្តម | **ស៊ុន ចាន់ថុល** | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | ប្រធាន |
| ២. ឯកឧត្តម | **ហ៊ាន សាហ៊ីប** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣. ឯកឧត្តម | **ស៊ា កុសល** | អនុរដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | អនុប្រធាន |
| ៤. ឯកឧត្តម | **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៥. ឯកឧត្តម | **ហ៊ូ តាំងអេង** | រដ្ឋលេខាធិការក្រសួងផែនការ | សមាជិក |
| ៦. ឯកឧត្តម | **សាត សាមី** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៧. ឯកឧត្តម | **ម៉ម អំណត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៨. ឯកឧត្តម | **សុខ ខាវ៉ាន់** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៩. ឯកឧត្តម | **ការ ច័ន្ទមេត្តា** | រដ្ឋលេខាធិការក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១០. ឯកឧត្តម | **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១១. ឯកឧត្តម | **ទិត ចន្ថា** | រដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១២. ឯកឧត្តម | **ជា ឧុទ្ធី** | អគ្គលេខាធិការរងនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ១៣. លោកជំទាវ | **អ៊ុក ម៉ាលី** | អគ្គទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា | សមាជិកា |
| ១៤. លោកជំទាវ | **ប៉ែន មុន្នីមករា** | អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិកា |
| ១៥. លោក | **ជា សុជាតិ** | ប្រធាននាយកដ្ឋានអឺរ៉ុប មជ្ឈឹមបូព៌ា និងអាហ្វ្រិក នៃក្រសួងពាណិជ្ជកម្ម | លេខាធិការ។ |

សមាជិកគណៈកម្មាធិការជាតិនេះ អាចត្រូវបានស្នើសុំបន្ថែមដោយប្រធានគណៈកម្មាធិការជាតិ ទៅតាមការចាំបាច់។

# ជំពូកទី៣
## តួនាទី និងភារកិច្ច

**មាត្រា៣ .-**

គណៈកម្មាធិការជាតិសម្រាប់កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មនិងសេដ្ឋកិច្ច កម្ពុជា-បេឡារុស មានតួនាទី និងភារកិច្ចដូចខាងក្រោម៖

- រៀបចំគោលនយោបាយ ផែនការសកម្មភាព និងយុទ្ធសាស្ត្រ សម្រាប់ជំរុញនិងគាំទ្រដល់ការពង្រីកកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់វិស័យពាណិជ្ជកម្មនិងសេដ្ឋកិច្ចទ្វេភាគី និងត្រូវធានាឱ្យគោលនយោបាយនិងកម្មវិធីទាំងឡាយ ស្របគ្នាជាមួយនឹងផែនការអភិវឌ្ឍន៍ជាតិរបស់រាជរដ្ឋាភិបាល។
- កំណត់នូវវិស័យសក្តានុពលនិងអាទិភាព សម្រាប់កិច្ចសហប្រតិបត្តិការកាន់តែជិតស្និទ្ធ រវាងប្រទេសទាំងពីរ លើពាណិជ្ជកម្មទំនិញ សេវាកម្ម វិនិយោគ និងវិស័យដទៃទៀត ដោយកំណត់ឱ្យបាននូវឱកាស បញ្ហាប្រឈម និងរបាំងចំពោះការអភិវឌ្ឍពាណិជ្ជកម្មនិងសេដ្ឋកិច្ច។
- ចូលរួមចរចា និងប្រជុំពិភាក្សាការងារជាមួយសមភាគីលើការងារទាក់ទងនឹងពាណិជ្ជកម្មនិងសេដ្ឋកិច្ច។

- ធ្វើសហប្រតិបត្តិការនិងសម្របសម្រួលជាមួយក្រសួង-ស្ថាប័ន វិស័យឯកជន និងភាគីពាក់ព័ន្ធដទៃទៀត ដើម្បីធានានូវប្រសិទ្ធភាព និងពង្រឹងនូវសង្គតិភាព និងកិច្ចសហប្រតិបត្តិការរវាងកម្ពុជា-បេឡារុស។
- សិក្សា-រៀបចំលើកគម្រោង និងកម្មវិធី ដែលត្រូវអភិវឌ្ឍដោយឡែក និងអភិវឌ្ឍរួម ដោយធ្វើការសម្របសម្រួលផ្ទៃក្នុង និងជាមួយបណ្តាប្រទេសផ្តល់ជំនួយ សំដៅរកថវិកាអនុវត្តគម្រោង។
- ធ្វើការទាក់ទាញ និងលើកទឹកចិត្តវិនិយោគិន ដើម្បីឱ្យមានការបណ្តាក់ទុននៅកម្ពុជា។
- ជំរុញការអនុវត្តសេចក្តីប្រកាសរួម និងកិច្ចព្រមព្រៀងដែលពាក់ព័ន្ធរវាងកម្ពុជា-បេឡារុស ព្រមទាំងពិនិត្យនិងលើកសំណើកែសម្រួល ឬធ្វើវិសោធនកម្មក្នុងករណីចាំបាច់។
- វាយតម្លៃលើការអនុវត្ត និងធ្វើរបាយការណ៍អំពីវឌ្ឍនភាពសកម្មភាពអនុវត្តការងារ និងលទ្ធផលការងារ ព្រមទាំងផ្តល់អនុសាសន៍តាមការចាំបាច់ជូនរាជរដ្ឋាភិបាល។
- ធ្វើរបាយការណ៍ស្តីពីលទ្ធផលការងារជូនប្រមុខរាជរដ្ឋាភិបាល តាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី។
- បំពេញការងារដទៃទៀត តាមការណែនាំរបស់ប្រមុខរាជរដ្ឋាភិបាល។

**មាត្រា៤ .-**

សមាជិកគណៈកម្មាធិការជាតិត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន។ ប្រធានគណៈកម្មាធិការជាតិ ត្រូវដឹកនាំអង្គប្រជុំ។ ក្នុងករណីប្រធានអវត្តមាន ប្រធានអាចប្រគល់ភារកិច្ចជូនអនុប្រធាន ឬតំណាង ដើម្បីដឹកនាំកិច្ចប្រជុំជំនួស។

## ជំពូកទី៤
## ការប្រព្រឹត្តទៅ

**មាត្រា៥ .-**

គណៈកម្មាធិការជាតិអាចអញ្ជើញតំណាងក្រសួង-ស្ថាប័ន វិស័យឯកជន អ្នកជំនាញការជាតិ និងអន្តរជាតិ ឬភាគីពាក់ព័ន្ធផ្សេងទៀត ដើម្បីពិគ្រោះយោបល់ ឬចូលរួមក្នុងកិច្ចប្រជុំរបស់ខ្លួន ឬចូលរួមក្នុងការងារសិក្សាស្រាវជ្រាវ ផ្តល់យោបល់ដើម្បីកែលម្អ និងធ្វើឱ្យកិច្ចសហប្រតិបត្តិការកាន់តែមានប្រសិទ្ធភាព។

**មាត្រា៦ .-**

ប្រធានគណៈកម្មាធិការជាតិមានសិទ្ធិបង្កើតអនុគណៈកម្មាធិការ ក្រុមការងារ និងក្រុមពិគ្រោះយោបល់ តាមការចាំបាច់ ដើម្បីជួយបំពេញការងាររបស់ខ្លួនឱ្យមានប្រសិទ្ធភាព។

សមាសភាព និងតួនាទីភារកិច្ចរបស់អនុគណៈកម្មាធិការ ក្រុមការងារ និងក្រុមពិគ្រោះយោបល់ ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិ។

**មាត្រា៧ .-**

គណៈកម្មាធិការជាតិមានលេខាធិការដ្ឋានមួយ ជាសេនាធិការ ស្ថិតនៅនាយកដ្ឋានអឺរ៉ុប មជ្ឈិមបូព៌ា និងអាហ្វ្រិកនៃក្រសួងពាណិជ្ជកម្ម។

លេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិ ត្រូវដឹកនាំដោយប្រធានលេខាធិការដ្ឋាន ០១ (មួយ) រូប និងមានអនុប្រធានមួយចំនួនតាមការចាំបាច់។

ការរៀបចំនិងការប្រព្រឹត្តទៅនៃលេខាធិការដ្ឋានរបស់គណៈកម្មាធិការជាតិ ត្រូវកំណត់ដោយប្រកាសរបស់ប្រធានគណៈកម្មាធិការជាតិ។

**មាត្រា៨ .-**

គណៈកម្មាធិការជាតិមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងពាណិជ្ជកម្ម ដើម្បីបំពេញការងាររបស់ខ្លួន។ ៧/…

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៩ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ស៊ុន ចាន់ថុល**

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**
ភ្នំពេញ,ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០១៤
**តប.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ឃឹម_សិរីវឌ្ឍ**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ